## កម្មវិធីសិក្សាបរិញ្ញាបត្រគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានធម្មជាតិ

| ឆ្នាំសិក្សាមូលដ្ឋាន (ឆ្នាំទី១) | |
|---|---|
| **ឆ្នាំទី២** | |
| ឆមាសទី១ | ឆមាសទី២ |
| ភាសាអង់គ្លេសទូទៅកម្រិត៣ | ភាសាអង់គ្លេសទូទៅកម្រិត៤ |
| អេកូឡូស៊ីកសិកម្ម | ការអប់រំ និងសុខភាព |
| ស្ថិតិអនុវត្តន៍១ | ស្ថិតិអនុវត្តន៍២ |
| សិទ្ធិមនុស្ស | គោលការណ៍សេដ្ឋកិច្ច |
| ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ | ការគ្រប់គ្រងធនធានសមុទ្រ |
| ការវាស់វែង និងការធ្វើបញ្ជីសារពើភ័ណ្ឌធនធានធម្មជាតិ | រុក្ខកម្ម និងការគ្រប់គ្រងព្រៃឈើ |
| ស្ថានប្រព័ន្ធ និងការប្រែប្រួលអាកាសធាតុ | ការគ្រប់គ្រងដីដោយនិរន្តរភាព |



| ឆ្នាំទី៣ | |
|---|---|
| ឆមាសទី១ | ឆមាសទី២ |
| ភាសាអង់គ្លេសទូទៅកម្រិត៥ | ភាសាអង់គ្លេសទូទៅកម្រិត៦ |
| យុវជន និងយេនឌ័រ | វិភាគសេដ្ឋកិច្ចតំបន់ |
| ពលរដ្ឋ និងការអភិវឌ្ឍ | ធនធានទឹក និងការចិញ្ចឹមជីវិត |
| ការគ្រប់គ្រងធនធានភាវីជាតិ | ការអភិរក្សជីវៈចម្រុះ |
| ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS-RS) | យេនឌ័រ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ |
| ការគ្រប់គ្រងចម្រុះធនធានទឹក | ការវាយតម្លៃសេដ្ឋកិច្ចធនធានធម្មជាតិ |
| ភូមិវិទ្យាធនធាន និងអភិបាលកិច្ច | ការវាយតម្លៃហេតុប៉ះពាល់សង្គម និង បរិស្ថាន |
| | កម្មសិក្សា |
| **ឆ្នាំទី៤** | |
| ឆមាសទី១ | ឆមាសទី២ |
| វិភាគគោលនយោបាយធនធានធម្មជាតិ | ការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ |
| ការគ្រប់គ្រងវិវាទធនធានធម្មជាតិ | ការគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| វិភាគការចិញ្ចឹមជីវិតនិងធនធានធម្មជាតិ | ផែនការប្រើប្រាស់ដីដោយការចូលរួម |
| ការទូទាត់សេវាកម្មអេកូឡូស៊ី | របាយការណ៍ស្រាវជ្រាវ |
| ស្ថិតិអនុវត្តន៍ SPSS | ឬ |
| វិធីសាស្ត្រស្រាវជ្រាវសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ | និក្ខេបបទបញ្ចប់ការសិក្សា |

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ROYAL UNIVERSITY OF PHNOM PENH

## មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍

Faculty of Development Studies



## ដេប៉ាតឺម៉ង់គ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានធម្មជាតិ

## Department of Natural Resource Management and Development (NRMD)

**អាសយដ្ឋានទំនាក់ទំនង:**
បន្ទប់លេខ ៣១៧A អគារ A មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០១៦ ៥០៦ ៨៨៨. ០១២ ៣៣៨ ០៤៤
Email: nrmd.info@rupp.edu.kh
FB: https://www.facebook.com/RUPP.FDS
Website: http://www.rupp.edu.kh/fds

## ដេប៉ាតឺម៉ង់គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ

កម្ពុជា ជាប្រទេសមានសក្តានុពលធនធានធម្មជាតិ និងជាគុណសម្បត្តិដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ។ ដើម្បីបន្តនិរន្តរភាព ក្នុងការប្រើប្រាស់ធនធានធម្មជាតិ យើងគប្បីបណ្តុះបណ្តាលធនធានមនុស្ស ដែលមានចំណេះដឹង ចំណេះធ្វើពិតប្រាកដធានាដល់ការការពារ អភិរក្ស ការប្រើប្រាស់សមស្រប និងការកែលម្អធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងសុខមាលភាពសង្គម និងដើម្បីកាត់បន្ថយភាពក្រីក្រ។

**ទស្សនៈវិស័យ៖**

កសាងធនធានមនុស្សប្រកបដោយបញ្ញា និងសីលធម៌ឈានមុខក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ ប្រកបដោយចីរភាព និងសមធម៌ ដើម្បីអភិវឌ្ឍប្រទេសជាតិ។

**បេសកកម្ម៖**

- កសាងសមត្ថភាពយល់ដឹងតាមទស្សនៈទាន និងគោលការណ៍វិទ្យាសាស្ត្រជាសកល
- ផ្សាភ្ជាប់ទ្រឹស្តី និងការអនុវត្តនៅមូលដ្ឋាន និងថ្នាក់តំបន់តាមរយៈកិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាស្រាវជ្រាវ
- បណ្តុះគំនិតច្នៃប្រឌិត និងទេពកោសល្យ

**ធនធានសាស្ត្រាចារ្យ៖**

ដេប៉ាតឺម៉ង់គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ ប្រមូល ផ្តុំទៅដោយធនធានបញ្ញវន្ត ដែលជាសាស្ត្រាចារ្យមានសមត្ថភាពខ្ពស់ ទទួលបានការអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត និងក្រោយបណ្ឌិត ពីបណ្តាប្រទេសអភិវឌ្ឍន៍លើ សកលលោកដែលទទួលបានជំនាញ និងបទពិសោធន៍ពីការអនុវត្តទាំងក្នុងស្រុក និងបណ្តាប្រទេសនានា។

**ចំណេះដឹង និងជំនាញ៖**

ក្រោយពីបញ្ចប់ការសិក្សានិស្សិតមានជំនាញ និងចំណេះដឹងដូចខាងក្រោម៖

- ទ្រឹស្តីមូលដ្ឋានសម្រាប់វិភាគបញ្ហាសង្គម និងយេនឌ័រ
- មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិ
- ទ្រឹស្តីអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព
- ជំនាញអភិរក្សជីវៈចម្រុះ
- ទ្រឹស្តីសេដ្ឋកិច្ចបរិស្ថាន និងធនធានធម្មជាតិ
- ចេះគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ និងសត្វព្រៃ
- ចេះវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន និងសង្គម
- ចេះវិភាគអំពីប្រែប្រួលអាកាសធាតុ និងនិរន្តភាពថាមពល
- ចេះគ្រប់គ្រង និងអាជីកម្មធនធានរ៉ែនិរន្តរភាព
- ចេះគ្រប់គ្រង និងអភិរក្សតំបន់ទីជម្រាល និងតំបន់ឆ្នេរ
- ចេះគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចិរភាព
- គ្រប់គ្រងចម្រុះធនធានទឹក និងការអភិវឌ្ឍវារីអគ្គិសនី
- អភិវឌ្ឍន៍តវិយាបថវិជ្ជមានចំពោះបរិស្ថាន
- ចេះធ្វើគម្រោងគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ
- ចេះវិភាគបញ្ហាសង្គម និងផ្តល់ជម្រើសសម្រាប់ដំណោះស្រាយ
- បង្កើនចំណេះដឹងផ្នែកភាសាអង់គ្លេសជំនាញ

**អត្ថប្រយោជន៍៖**

ក្រៅពីទទួលបានទ្រឹស្តី និងការអនុវត្ត និស្សិតអាចទទួលបានឱកាសទាំងមុន និងក្រោយពេលបញ្ចប់ការសិក្សានៅដេប៉ាតឺម៉ង់គ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានធម្មជាតិដូចជា៖

- ចូលរួមក្នុងកិច្ចការសិក្សាស្រាវជ្រាវក្នុងគម្រោងស្រាវជ្រាវ ឬវាយតម្លៃ ផ្សេងៗ ជាមួយសាស្ត្រាចារ្យ និងជំនាញការបរទេស
- ចូលរួមសិក្ខាសាលា ឬសន្និបាតវិទ្យាសាស្ត្រនានា
- ជ័យលាភី ឬរង្វាន់ក្នុងការប្រកួតប្រជែងនានា
- បន្តការសិក្សានៅក្រៅប្រទេស

- ចុះអនុវត្ត និង កម្មសិក្សាជាក់ស្តែង ក្នុងវិស័យសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា

**ទីផ្សារការងារ៖**

- ស្ថាប័នរាជរដ្ឋាភិបាល (ជាសាស្ត្រាចារ្យ និងអ្នកឯកទេស)
- អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ
- ក្រុមហ៊ុនឯកជនជាតិ និងអន្តរជាតិ
- គ្រឹះស្ថានអប់រំ និងស្រាវជ្រាវសាធារណៈ និងឯកជន
- ការងារស្រាវជ្រាវ និងប្រឹក្សាយោបល់

**ធនធានសម្រាប់សិក្សា៖**

- ជាសាកលវិទ្យាល័យឈានមុខថ្នាក់ជាតិ
- មានការទទួលស្គាល់ទូទាំងសកលលោក
- មានទីធ្លាធំទូលាយ និងបរិស្ថានសិក្សាល្អ
- សៀវភៅសិក្សាទំនើបៗ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- ផ្តល់ជូននូវការប្រើប្រាស់អ៊ិនធើណិតដោយឥតគិតថ្លៃ
- ឯកសារសិក្សាស្រាវជ្រាវ នៅបណ្ណាល័យសម្តេចហ៊ុន សែន បណ្ណាល័យ នៅតាមមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់នានា

**លក្ខខណ្ឌចុះឈ្មោះចូលរៀន៖**

និស្សិតត្រូវមានសញ្ញាបត្រទុតិយភូមិ និងមាននិទ្ទេសទៅតាមមុខវិជ្ជាដូចខាងក្រោម៖

១. ផែនដីវិទ្យា និទ្ទេស A-E

២. ភាសាអង់គ្លេស និទ្ទេស A-E

៣. ចំពោះនិស្សិតបង់ថ្លៃ: ជាប់សញ្ញាបត្រទុតិយភូមិគ្រប់និទ្ទេស (មិនគិតមុខវិជ្ជា)

**ចំពោះនិស្សិតបង់ថ្លៃ៖**

តម្លៃ ៥០០ដុល្លារ (USD)/ឆ្នាំ ។